# ព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម




ឆ្នាំទី៣១ លេខ៧៤៣ ខែសីហា ឆ្នាំ២០២៤

# មាតិកា

## ០១ ស្ថិតិពាណិជ្ជកម្ម


១.១. សន្ទស្សន៍ថ្លៃទំនិញនៅលើទីផ្សាររាជធានីភ្នំពេញប្រចាំខែសីហា ឆ្នាំ២០២៤....................................០១
១.២. ការចុះបញ្ជីសហគ្រាសពាណិជ្ជកម្ម..........................................................................................០៣
១.៣. ការចុះបញ្ជីម៉ាកពាណិជ្ជនាម...................................................................................................០៥
១.៤. វិស័យនាំចេញរបស់កម្ពុជា.......................................................................................................០៧
១.៥. តម្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗលើទីផ្សារអន្តរជាតិប្រចាំខែសីហា ឆ្នាំ២០២៤.........................១១


## ០២ អត្ថបទស្រាវជ្រាវ


ការជំរុញការដាក់ផលិតផលកម្ពុជានៅលើទីផ្សារអនឡាញដ៏ធំលើពិភពលោក អាលីបាបា៖......................១៦


## ០៣ ព័ត៌មានរបស់ក្រសួងពាណិជ្ជកម្ម


សកម្មភាពថ្នាក់ដឹកនាំ.......................................................................................................................១៨


## ០៤ ព័ត៌មានទីផ្សារអន្តរជាតិ


ខឿនសេដ្ឋកិច្ចទីពីរលើពិភពលោកកំពុងជំរុញវិស័យផលិតបន្ទះឈិប( chip )........................................២០

# ១-ស្ថិតិពាណិជ្ជកម្ម

## ◆ ១.១ សន្ទស្សន៍ថ្លៃទំនិញ នៅលើទីផ្សាររាជធានីភ្នំពេញ៖

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំជីវភាព នៅលើទីផ្សាររាជធានីភ្នំពេញប្រចាំខែកក្កដា ឆ្នាំ២០២៤មានដូចជា៖(នៅលើទីផ្សារធំថ្មី, កណ្តាល, ច្បារអំពៅ, ដើមគរ, និងផ្សារអូរឫស្សី)។

- តារាងប្រៀបធៀបសន្ទស្សន៍តម្លៃទំនិញប្រចាំជីវភាពនៅលើទីផ្សារ (ឯកតា៖ គិតជារៀល)

| ទំនិញ | ឯកតា | ខែកក្កដា ឆ្នាំ២០២៤ | ខែសីហា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| អង្ករផ្កាម្លិះ | គីឡូ/រៀល | 3,800 | 3,850 | 50 | 0.01 |
| អង្ករនាងម៉ិញ | គីឡូ/រៀល | 3,000 | 3,000 | - | - |
| សាច់គោ | គីឡូ/រៀល | 38,000 | 38,500 | 500 | 0.01 |
| សាច់ជ្រូក | គីឡូ/រៀល | 20,000 | 20,000 | - | - |
| សាច់មាន់ | គីឡូ/រៀល | 27,000 | 26,500 | -500 | -0.02 |
| ត្រីរស់ស្រស់ | គីឡូ/រៀល | 12,500 | 12,500 | - | - |

- តម្លៃអង្ករ៖ តម្លៃអង្ករលក់នៅលើទីផ្សារទាំង៥ ក្នុងរាជធានីភ្នំពេញ សម្រាប់ខែសីហា ប្រៀបធៀបទៅនឹងខែកក្កដា ឆ្នាំ២០២៤ នេះឃើញថាតម្លៃអង្ករផ្កាម្លិះមានការកើនឡើង ០,០១% និងអង្ករនាងម៉ិញមានតម្លៃថេរ។
- តម្លៃម្ហូបអាហារ៖ តម្លៃម្ហូបអាហារ នៅលើទីផ្សារទាំង៥ក្នុងរាជធានីភ្នំពេញ សម្រាប់ខែសីហា បើធៀបទៅនឹងខែកក្កដា ឆ្នាំ២០២៤ ពុំមានការប្រែប្រួលទៅលើមុខទំនិញដូចជា៖ សាច់គោមានការកើន០,០១% សាច់ជ្រូកមានតម្លៃថេរ សាច់មាន់មានការថយចុះ០,០២% និងត្រីរស់ស្រស់មានតម្លៃថេរ។
- រីឯនៅតំបន់អាស៊ី ជាទីកន្លែងប្រមូលផ្តុំមួយភាគធំនៃបរិមាណផលិតផលអង្ករពិភពលោក ហើយប្រទេសឥណ្ឌាឈានមួយជំហានមុនប្រទេសចិនប្រែក្លាយទៅជាប្រទេសនាំចេញអង្ករច្រើនបំផុតលើពិភពលោក។ ប្រទេសចិនឈរជួរទីពីរបន្ទាប់ គឺប្រទេសឥណ្ឌូនេស៊ី ថៃ និងវៀតណាម។ នៅទសវត្សរ៍ខាងមុខ បរិមាណអង្ករនាំចេញពីអាស៊ីខាងត្បូង និងអាស៊ីអគ្នេយ៍ទទួលបានកំណើនខ្ពស់ ជាមួយនឹងល្បឿនជាមធ្យមប្រចាំឆ្នាំ ២,៨% ធ្វើឲ្យបរិមាណអង្ករនាំចេញរបស់ពិភពលោកកើនដល់ ៨៦% ។

ប្រភព៖ Webside vinanet



- **តម្លៃប្រេងឥន្ធនៈ៖**

តារាងប្រៀបធៀបសន្ទស្សន៍តម្លៃប្រេងឥន្ធនៈនៅលើទីផ្សារ

(ឯកតា៖ គិតជារៀល)

| ទំនិញ | ឯកតា | ខែកក្កដា ឆ្នាំ២០២៤ | ខែសីហា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| សាំងស៊ុបពែ | លីត្រ/រៀល | 4,950 | 4,700 | -250 | -0.05 |
| សាំងធម្មតា | លីត្រ/រៀល | 4,300 | 4,100 | -200 | -0.05 |
| ប្រេងម៉ាស៊ូត | លីត្រ/រៀល | 4,200 | 4,000 | -200 | -0.05 |
| ហ្គាស | ១៥គីឡូ/រៀល | 70,000 | 68,000 | -2,000 | -0.03 |







- ប្រេងឥន្ធនៈ៖ តម្លៃប្រេងឥន្ធនៈនៅបណ្តាស្ថានីយ៍ក្រុមហ៊ុនទាំង៩ របស់កម្ពុជាដូចជា ក្រុមហ៊ុនកម្ពុជាតេលា សូគីម៉ិច ភីធីធី តូតាល់ ឈេហ្វ្រុន សាវីម៉ិច ប៊ីវីអឹម អិលអេចអរ និងក្រុមហ៊ុនប៉ាប៉ា ក្នុងបណ្តារាជធានីភ្នំពេញ-ខេត្ត សម្រាប់ខែសីហា ធៀបទៅនឹងខែកក្កដា ឆ្នាំ២០២៤ តម្លៃសាំងស៊ុបពែបានថយ០,០៥%, សាំងធម្មតាបានថយ០,០៥% និងប្រេងម៉ាស៊ូតបានថយ ០,០៥% និងតម្លៃហ្គាសមានការថយចុះ ០,០៣%។
- នៅក្នុងខែសីហា នេះ តម្លៃប្រេងឆៅ Brent បានថយចុះជាមធ្យម ៦,១០% ក្រោយពីតួលេខស្ថិតិបានបង្ហាញឲ្យដឹងថា បរិមាណផលិតផលប្រេងស្តុកឃ្លាំងរបស់អាមេរិកបានកើនឡើង ៨៤៦០០០ធុង និងនៅមជ្ឈមណ្ឌលចំរាញ់ប្រេង Amsterdam-Rotterdam -Antwerp (ARA) របស់អឺរ៉ុប បានកើន ១,១% ជាមធ្យម។

ប្រភព៖ Website Vinanet

## ១.២ ការចុះបញ្ជីសហគ្រាសពាណិជ្ជកម្ម

- តារាងប្រៀបធៀបចំនួនក្រុមហ៊ុន ដែលបានចុះបញ្ជីពាណិជ្ជកម្មក្នុងខែកក្កដា ធៀបទៅនឹងខែមិថុនា ឆ្នាំ២០២៤

(ឯកតា៖ ចំនួនក្រុមហ៊ុន)

| ប្រភេទក្រុមហ៊ុន | ខែកក្កដា ឆ្នាំ២០២៤ | ខែសីហា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|
| **ករណីស្នើសុំចុះបញ្ជីពាណិជ្ជកម្ម(ថ្មី)** | | | | |
| ក្រុមហ៊ុនមូលធន | 441 | 469 | 28 | 0.06 |
| ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | 4 | 2 | -2 | -0.50 |
| សហគ្រាសឯកបុគ្គល | 427 | 411 | -16 | -0.04 |
| **ករណីស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក** | | | | |
| លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | 1 | 3 | 2 | 2 |
| លិខិតអនុញ្ញាតសហគ្រាសឯកបុគ្គល | 1 | 1 | - | - |
| អាជ្ញាបណ្ណ | 2 | 2 | - | - |
| **ករណីស្នើសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម** | | | | |
| ក្រុមហ៊ុនមូលធន | 114 | 146 | 32 | 0.28 |
| ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | 2 | 3 | 1 | 0.50 |
| សហគ្រាសឯកបុគ្គល | 17 | 26 | 9 | 0.53 |
| **ករណីស្នើសុំចុះបញ្ជីកែប្រែ** | | | | |
| កែប្រែប្តូរភាគហ៊ុន បន្ថយបង្កើនដើមទុន | 193 | 209 | 16 | 0.08 |
| ការកែប្រែផ្សេងៗ (អភិបាល កម្មវត្ថុ .....) | 986 | 980 | -6 | -0.01 |
| ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | 37 | 36 | -1 | -0.03 |
| ការកែប្រែសហគ្រាសឯកបុគ្គល | 67 | 59 | -8 | -0.12 |

### ក្រាហ្វិកករណីស្នើសុំចុះបញ្ជីពាណិជ្ជកម្ម (ថ្មី)




### ក្រាហ្វិកករណីស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក




### ក្រាហ្វិកករណីស្នើសុំលុបឈ្មោះ




### ក្រាហ្វិកស្នើសុំចុះបញ្ជីកែប្រែ



## ១.៣ ការចុះបញ្ជីម៉ាកពាណិជ្ជនាមៈ

- តារាងប្រៀបធៀបចំនួនម៉ាកពាណិជ្ជនាមដែលបានចុះបញ្ជីនៅក្នុងខែកក្កដា ធៀបទៅនឹងខែមិថុនា ឆ្នាំ២០២៤

(ឯកតា៖ គិតជាចំនួនម៉ាក)

| ការផ្តល់សេវាផ្សេងៗ ពាក់ព័ន្ធ និងកិច្ចការពារម៉ាក | ខែកក្កដា ឆ្នាំ២០២៤ | ខែសីហា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|
| **ការចុះបញ្ជីម៉ាក**(Registration) | | | | |
| ក្នុងស្រុក | 194 | 179 | -15 | -0.08 |
| ក្រៅស្រុក | 223 | 208 | -15 | -0.07 |
| ការបដិសេធចុងក្រោយ និងបោះបង់ចោល | 64 | 67 | 3 | 0.05 |
| ការស្នើផ្លាស់ប្តូរម៉ាក | 12 | 16 | 4 | 0.33 |
| ការស្នើផ្លាស់ប្តូរទំនិញ រឺសេវ៉ា | 8 | - | -8 | 1.00 |
| ការស្នើផ្លាស់ប្តូរឈ្មោះអ្នកស្នើសុំ | - | - | - | - |
| ការស្នើផ្លាស់ប្តូរអាសយដ្ឋាន | - | - | - | - |
| ការស្នើផ្លាស់ប្តូរសុំពន្យារពេល | 15 | 23 | 8 | 0.53 |
| **ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ** (Madrid system) | | | | |
| សុំចុះបញ្ជីម៉ាកពីប្រទេសហត្ថលេខីតាមប្រព័ន្ធចុះបញ្ជីម៉ាកអន្តរជាតិ | 213 | 312 | 99 | 0.46 |
| ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ(Madrid system) | 209 | 325 | 116 | 0.56 |
| ការផ្លាស់ប្តូរផ្សេងៗតាមប្រព័ន្ធអន្តរជាតិ (Madrid system) | 174 | 139 | -35 | -0.20 |

**ក្រាហ្វិកការចុះបញ្ជីម៉ាកពាណិជ្ជនាម** ( Registration )




**ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ** ( Madrid system )



## ១.៤ វិស័យនាំចេញរបស់កម្ពុជា

- **ការនាំចេញផលិតផលពីកម្ពុជា ទៅបណ្តាប្រទេសក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី**( Cambodian Export Under FTA GSP and MFN Scheme )

តារាងប្រៀបធៀបតម្លៃផលិតផលនាំចេញពីកម្ពុជាទៅបណ្តាប្រទេស ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

( ឯកតា៖ ដុល្លារអាមេរិក )

| ប្រភេទទំនិញ | ខ្នាត | ខែកក្កដា ឆ្នាំ២០២៤ | ខែសីហា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| សំលៀកបំពាក់ | DOZ | 777,827,376 | 791,329,742 | 13,502,366 | 0.02 |
| វាយនភ័ណ្ឌ | N/A | 9,180,784 | 8,557,095 | -623,689 | -0.07 |
| ស្បែកជើង | PRS | 148,164,459 | 143,021,150 | -5,143,309 | -0.03 |
| កាបូបធ្វើដំណើរ | DOZ | 159,566,257 | 164,472,283 | 4,906,026 | 0.03 |
| កង់ | SET | 30,856,379 | 34,936,528 | 4,080,149 | 0.13 |
| អង្ករ | N/A | 91,832,582 | 87,152,216 | -4,680.366 | -0.05 |
| ទំនិញកសិកម្ម | - | 123,914,860 | 118,835,699 | -5,079,161 | 0.04 |
| ផលិតផលផ្សេងៗ | N/A | 773,285,274 | 831,545,380 | 58,260,106 | 0.08 |
| **សរុបរួម** | | **2,114,627,971** | **2,179,850,093** | **65,222,122** | **0.03** |

- ប្រភពនាយកដ្ឋាននាំចេញ នាំចូល៖ តួលេខនាំចេញនេះ ជាតួលេខដែលទទួលបានក្រោមការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ។

## ក្រាហ្វិកតម្លៃផលិតផលនាំចេញពីកម្ពុជាទៅបណ្តាប្រទេស ក្រោមប្រព័ន្ធ អនុគ្រោះពាណិជ្ជកម្ម និងពាណិជ្ជកម្មសេរី លើទីផ្សារពិភពលោក






- **ប្រទេសនាំចេញទំនិញពីកម្ពុជា ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី**( Cambodian Export Under FTA GSP and MFN Scheme )

តារាងប្រៀបធៀបប្រទេសនាំចេញតម្លៃទំនិញពីកម្ពុជាទៅបណ្តាប្រទេស ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (ឯកតា៖ ដុល្លារអាមេរិក)

| **ប្រទេស** | **ខែកក្កដា ២០២៤** | **ខែសីហា ២០២៤** | **កើន(+) ថយ(-)** | **ភាគរយ (%)** |
|---|---|---|---|---|
| អាមេរិក | 838,752,228 | 941,563,754 | 102,811,526 | 0.12 |
| អង់គ្លេស | 155,149,325 | 92,743,359 | -62,405,966 | -0.40 |
| សហគមន៍អឺរ៉ុប | 285,453,582 | 295,714,440 | 10,260,858 | 0.04 |
| កាណាដា | 91,873,417 | 102,185,379 | 10,311,962 | 0.11 |
| អាស៊ាន | 369,067,842 | 320,296,569 | -48,771,273 | -0.13 |
| ជប៉ុន | 88,218,235 | 148,847,727 | 60,629,492 | 0.69 |
| ចិន | 149,185,971 | 154,989,318 | 5,803,347 | 0.04 |
| អូស្ត្រាលី | 15,698,294 | 13,573,662 | -2,124,632 | -0.14 |
| ឥណ្ឌា | 22,360,822 | 13,519,909 | -8,840,913 | -0.40 |
| ណូវែលហ្សេឡង់ | 1,707,367 | 2,415,723 | 708,356 | 0.41 |
| អារ៉ាប៊ីសាអូឌីត | 5,828,058 | 3,166,237 | -2,661,821 | -0.46 |
| កូរ៉េ | 25,202,386 | 31,708,004 | 6,505,618 | 0.26 |
| បណ្តាប្រទេសផ្សេងៗក្នុងពិភពលោក | 66,130,444 | 59,127,013 | -7,003,431 | -0.11 |
| **សរុបរួម** | **2,114,627,971** | **2,179,850,093** | **65,223,123** | **0.03** |

- ប្រភពនាយកដ្ឋាននាំចេញ នាំចូល៖ តួលេខនាំចេញនេះ ជាតួលេខដែលទទួលបាន ក្រោមការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ។

## ក្រាហ្វិកការនាំចេញរបស់កម្ពុជា






## ១.៥ តម្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗ លើទីផ្សារអន្តរជាតិប្រចាំខែសីហាឆ្នាំ២០២៤

- **អង្ករ៖**

(ឯកតា៖ ដុល្លារអាមេរិក/តោន)

| មុខទំនិញ | លក្ខខណ្ឌប្រគល់-ទទួល | ខែកក្កដា ឆ្នាំ២០២៤ | ខែសីហា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| អង្ករប្រភេទបាក់5% | FOB Bangkok | 578 | 572 | -6 | -1.04 |
| អង្ករប្រភេទបាក់5% | FOB Vietnam | 551 | 574 | 23 | 4.17 |
| អង្ករប្រភេទបាក់5% | FOB India | 555 | 555 | - | - |
| អង្ករប្រភេទបាក់5% | FOB មីយ៉ាន់ម៉ា | 573 | 534 | -39 | -6.81 |
| អង្ករប្រភេទបាក់5% | FOB USA | 822 | 777 | -45 | -5.47 |
| អង្ករប្រភេទបាក់5% | FOB ប៉ាគីស្ថាន | 587 | 538 | -49 | -8.35 |
| អង្ករប្រភេទបាក់25% | FOB Bangkok | 530 | 522 | -8 | -1.51 |
| អង្ករប្រភេទបាក់25% | FOB Vietnam | 522 | 535 | 13 | 2.49 |
| អង្ករប្រភេទបាក់25% | FOB India | 540 | 540 | - | - |
| អង្ករក្រហមប្រភេទ (Hommali) 100% | FOB Bangkok | 545 | 578 | -7 | -1.20 |
| អង្ករក្រហមប្រភេទ5% | FOB India | 562 | 562 | - | - |
| អង្ករហូមមាលីប្រភេទ (hommali)100% | FOB Bangkok | 825 | 852 | 27 | 3.27 |
| អង្ករក្រអូប | FOB Vietnam | 618 | 667 | 49 | 7.93 |

- កត់សំគាល់៖ តម្លៃអង្ករលក់ចេញនៅទីផ្សារសំខាន់ៗនៅក្នុងខែសីហា ឆ្នាំ២០២៤នេះ គឺមានការប្រែប្រួលធៀបទៅនឹង ខែកក្កដា ឆ្នាំ២០២៤។
- នៅក្នុងខែសីហា នេះ នៅប្រទេសថៃ តម្លៃអង្ករនាំចេញបានថយចុះពី ៦ទៅ៨ដុល្លារ/តោន(FOB, Bangkok)ធៀបទៅនឹងខែកក្កដា ដោយអង្ករប្រភេទបាក់៥% លក់ចេញក្នុងតម្លៃ ៥៧២ដុល្លារ/តោន(FOB, Bangkok) និងប្រភេទ ២៥% លក់ចេញក្នុងតម្លៃ ៥២២ដុល្លារ/តោន (FOB, Bangkok) និងអង្ករប្រភេទហូមមាលី១០០% លក់ចេញក្នុងតម្លៃ ៨៥២ ដុល្លារ/តោន(FOB, Bangkok)ប្រភេទ។

- ផ្ទុយទៅវិញនៅវៀតណាមតម្លៃអង្ករនាំចេញបានកើនឡើងពី ១៣ទៅ ៤៩ដុល្លារ/តោន(FOB, កំពង់ផែក្រុងហូជីមិញ) ធៀបខែបន្ទាប់ ដោយអង្ករប្រភេទ ៥% លក់ចេញក្នុងតម្លៃ ៥៧៤ដុល្លារ/តោន (FOB, Vietnam) និងអង្ករប្រភេទក្រអូបលក់ចេញក្នុងតម្លៃ មធ្យម ៦៦៧ដុល្លារ/តោន (FOB, កំពង់ផែក្រុងហូជីមិញ)។ ប្រភេទ២៥% លក់ចេញក្នុងតម្លៃជាមធ្យម ៥៣៥ដុល្លារ/តោន(FOB, កំពង់ផែក្រុងហូជីមិញ)។ នៅក្នុងខែសីហា នេះ តម្លៃអង្ករនាំចេញនៅទីផ្សារមានការប្រែប្រួលទៅតាមតំបន់ តម្លៃអង្ករនាំចេញរបស់ប្រទេសជិតខាងវៀតណាម បានធ្លាក់ថ្លៃធៀបទៅនឹងខែបន្ទាប់ បើតាមឈ្មួញអង្ករនៅទីក្រុងហូជីមិញបានឲ្យដឹងថា ៖ ប្រភពផ្គត់ផ្គង់កំពុងមានការខ្វះខាត ព្រោះតែរដូវប្រមូលផលរដូវរំហើយនៅតំបន់ទំនាបទន្លេគីវឡុងជិតបានបញ្ចប់ ខណៈនេះដែររដូវភ្លៀងធ្លាក់ បានអូសបន្លាយ បានជះឥទ្ធិពលដល់គុណភាពអង្ករ។ តាមសារព័ត៌មាន Reuters បាននាំពាក្យរបស់ក្រុមហ៊ុនអង្ករអន្តរជាតិដែលមានស្នាក់ការនៅទីក្រុង Mumbai បានឲ្យដឹងថាតម្រូវការនាំចេញរបស់ឥណ្ឌាពីសំណាក់អតិថិជនបានថយចុះឥណ្ឌាបានបង្កើនតម្លៃទិញអង្កររដូវវស្សាពីកសិករក្នុងតម្លៃបន្ថែម ៥,៤% គឺឡើងដល់ ២៣00rupee/១00គីឡូក្រាម។ ស្របពេលជាមួយគ្នានេះដែរ អង្ករប្រភេទ ៥% របស់ប្រទេសថៃ លក់ចេញក្នុងតម្លៃជាមធ្យម ៥៧0 ដុល្លារ/តោន ការផ្លាស់ប្តូរតម្លៃអង្ករនាំចេញ មួយផ្នែកផ្អែកទៅលើអត្រាប្តូរប្រាក់បីយ៍បណ្ណ៍ខណៈដែលតម្រូវការអង្ករមានស្ថេរភាព។
- នៅតំបន់អាស៊ី ជាទីកន្លែងប្រមូលផ្តុំមួយភាគធំនៃបរិមាណផលិតផលអង្ករពិភពលោក ហើយប្រទេសឥណ្ឌាឈានមួយជំហានមុនប្រទេសចិនប្រែក្លាយទៅជាប្រទេសនាំចេញអង្ករច្រើនបំផុតលើពិភពលោក។ ប្រទេសចិនឈរជួរទីពីរបន្ទាប់គឺប្រទេសឥណ្ឌូនេស៊ី ថៃ និងវៀតណាម។ នៅទសវត្សរ៍ខាងមុខ បរិមាណអង្ករនាំចេញពីអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ទទួលបានកំណើនខ្ពស់ ជាមួយនឹងល្បឿនជាមធ្យមប្រចាំឆ្នាំ ២,៨% ធ្វើឲ្យបរិមាណអង្ករនាំចេញរបស់ពិភពលោកកើនដល់ ៨៦% ។

- **កសិផល៖**

(ឯកតា៖ដុល្លារអាមេរិក/តោន)

| មុខទំនិញ | លក្ខខណ្ឌប្រគល់-ទទួល | ខែកក្កដា ឆ្នាំ២០២៤ | ខែសីហា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| ស្រូវសាលី | FOB USA | 212.50 | 201.36 | -11.14 | -5.24 |
| ពោត | - | 155.50 | 145.51 | -9.99 | -6.42 |
| សណ្តែកសៀង | - | 406.70 | 367.00 | -39.7 | -9.76 |
| ប្រេងដូងមិនទាន់កែច្នៃ | FOB Malaysia | 847.69 | 865.50 | 17.81 | 2.10 |
| ប្រេងសណ្តែកសៀង | CIF Rotterdam | 975.05 | 932.54 | -42.51 | -4.36 |
| គ្រាប់ម្រេចខ្មៅ | FOB (V.N) | 3,450.00 | 3,610.00 | 160 | 4.64 |
| គ្រាប់ម្រេចស | FOB (V.N) | 4,390.00 | 4,505.00 | 115 | 2.62 |

| | | | | | |
|---|---|---|---|---|---|
| កាហ្វេ(ROBUSTA) | FOB New York(USA) | 4,498 | 4,261.00 | -237 | -5.27 |
| កាហ្វេ(ARABICA) | London | 5,994.15 | 5,451.50 | -542.65 | -9.05 |
| កប្បាសលេខ២ | FOB New York | 1,601.51 | 1,540.40 | -61.11 | -3.82 |
| កាកាវ(ដុល្លារ/តោន) | CIF New York (USA) | 7,731 | 7,613.00 | -118 | -1.53 |

- កត់សំគាល់៖ តម្លៃកសិផលគ្រប់ប្រភេទមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ នៅខែសីហា ឆ្នាំ២០២៤នេះ។
- តម្លៃពោត៖ នៅក្នុងខែសីហា នេះ តម្លៃពោតនាំចេញនៅ Chicago បានថយចុះជាមធ្យម ៩,៩៩ដុល្លារ/តោន (៦,៤២%) ធៀបខែមុន ដោយលក់ចេញក្នុងតម្លៃ ១៤៥,៥១ ដុល្លារ/តោន (FOB, Chicago)។
- តម្លៃស្រូវសាលី៖ តម្លៃស្រូវសាលីនាំចេញនៅ Chicago បានថយចុះជាមធ្យម ១១,១៤ដុល្លារ/តោន (៩,៦៦%) ធៀបខែកក្កដា ដោយលក់ចេញក្នុងតម្លៃជាមធ្យម២០១,៣៦ដុល្លារ/តោន (FOB Chicago)។
- តម្លៃសណ្ដែកសៀង៖ នៅ Chicago តម្លៃសណ្ដែកសៀងនាំចេញបានថយ ៣៩,៧០ដុល្លារ/តោន(៩,៧៦%) ដោយលក់ចេញក្នុងតម្លៃមធ្យម ៣៦៧,០០ដុល្លារ/តោន, FOB Chicago។
- តម្លៃប្រេងដូងប្រេង៖ តម្លៃប្រេងដូងប្រេងនៅទីផ្សារប្រទេសម៉ាឡេស៊ីនៅក្នុងខែសីហា ឆ្នាំ២០២៤ បានកើន ១៧,៨១ ដុល្លារ/តោន (២,១០%) ដោយលក់ចេញក្នុងតម្លៃមធ្យម ៨៦៥,៥០ដុល្លារ/តោន (FOB, Malaysia )។
- តម្លៃកាហ្វេ៖ នៅខែសីហា នេះតម្លៃកាហ្វេនាំចេញគ្រប់ប្រភេទបានថយចុះ ធៀបទៅនឹងខែមុន។ នៅទីផ្សារ New York តម្លៃកាហ្វេរ៉ូប៊ូស្តារលក់ចេញបានថយ ២៣៧,០០ដុល្លារ/តោន (៥,២៧%) ដោយលក់ចេញក្នុងតម្លៃមធ្យម ៤.២៦១,០០ដុល្លារ/តោន, FOB(ទីផ្សារ New York) និងនៅក្រុងឡុងដ៍តម្លៃកាហ្វេអារ៉ាប៊ីកាលក់ចេញបានថយ ៥៤២,៦៥ដុល្លារ/តោន (៩,០៥%) ដោយលក់ចេញក្នុងតម្លៃមធ្យម ៥.៤៥១,៥០ដុល្លារ/តោន(FOB, ទីផ្សារឡុងដុង)។ នៅក្នុងខែសីហា នេះ តម្លៃកាហ្វេគ្រប់ប្រភេទបានថយចុះ ក្រោយពីប្រាក់ Real ប្រេស៊ីលបានធ្លាក់ថ្លៃធៀបទៅនឹងប្រាក់ដុល្លារអាមេរិក គឺស្ថិតក្នុងតម្លៃ ៥,៦២Real/ដុល្លារ ជាមធ្យម។ ទន្ទឹមនេះដែរ បរិមាណផលិតផលកាហ្វេនាំចេញរបស់ពិភពលោកបានកើនឡើងយ៉ាងគំហុក បានជះឥទ្ធិពលខ្លាំងដល់តម្លៃនៅលើទីផ្សារនាំចេញ។ ក្រោយពីសមាគមកាហ្វេអន្តរជាតិ (ICO) បានប្រកាសឲ្យដឹងថា បរិមាណនាំចេញកាហ្វេពិភពលោកបានកើនឡើង ១២,២% ធៀបរយៈពេលដូចគ្នានាឆ្នាំមុន និងនៅក្នុងខែកក្កដាកន្លងទៅ ឡើងដល់ ១១,២៩លានបាវ និងការនាំចេញចាប់ពីខែតុលា ឆ្នាំ២០២៣ ដល់ខែកក្កដាឆ្នាំ២០២៤នេះ បានកើន ១០,៥% ធៀបរយៈពេលដូចគ្នានាឆ្នាំមុន គឺ កើនដល់ចំនួន ១១៥,០១លានបាវ ។

- **ផលិតផលឧស្សាហកម្ម៖**

(ឯកតា៖ដុល្លារអាម៉េរិក/តោន)

| មុខទំនិញ | លក្ខខណ្ឌ ប្រគល់-ទទួល | ខែកក្កដា ឆ្នាំ២០២៤ | ខែសីហា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| ស្ករស | CIF London | 575.20 | 532.55 | -42.65 | -7.41 |
| កៅស៊ូប្រភេទRSS3 | FOB HCM(vn) | 1,894 | 2,250.00 | 356 | 18.80 |

| មុខទំនិញ | លក្ខខណ្ឌប្រគល់-ទទួល | ខែកក្កដា ឆ្នាំ២០២៤ | ខែសីហា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| កៅស៊ូប្រភេទ RSS3 | FOBBangkok | 2,127 | 2,400.00 | 273 | 12.83 |
| កៅស៊ូប្រភេទ RSS3 | FOB Shanghai | 2,008 | 2,279.00 | 271 | 13.50 |
| កៅស៊ូប្រភេទ RSS3 | FOB Tokyo | 2,040 | 2,355.00 | 315 | 15.44 |
| កៅស៊ូប្រភេទ SMRCV | FOB Malaysia | 1,750 | 1,825.00 | 75 | 4.29 |
| កៅស៊ូប្រភេទ SIR20 | FOB Indonesia | 1,690 | 1,795.00 | 105 | 6.21 |

- កត់សំគាល់៖ តម្លៃទំនិញឧស្សាហកម្មមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ ពិសេសតម្លៃស្ករស និងតម្លៃកៅស៊ូធម្មជាតិនៅក្នុងខែសីហា ឆ្នាំ២០២៤នេះ។
- តម្លៃស្ករស៖នៅក្នុងខែសីហា ឆ្នាំ២០២៤ នេះទីផ្សារឡុងដ៍តម្លៃស្ករសលក់ចេញបានថយចុះជាមធ្យម៤២,៦៥ដុល្លារ/តោន(៧,៤១%)ធៀបទៅនឹងខែមុនដោយលក់ចេញក្នុងតម្លៃ ៥៣២,៥៥ដុល្លារ/តោន(FOB, ឡុងដុង)ដោយសារប្រភពផ្គត់ផ្គង់កើនឡើងលើសពីតម្រូវការប្រើប្រាស់។ នៅរដូវឆ្នាំ២០២៣-២៤ បរិមាណផលិតផលអំពៅរបស់ថៃទទួលបានចំនួន ៨២,១លានតោន ស្មើនឹង ៨,៨លានតោនស្ករ និងនៅដើមឆ្នាំ២០២៤ ទីផ្សារប្រើប្រាស់ស្ករចំនួនតែ ១,២៧លានតោនប៉ុណ្ណោះ ហើយបរិមាណដែលនៅសល់ គឺ ធ្វើការនាំចេញ។ បើតាមក្រសួងពាណិជ្ជកម្មថៃ បានឲ្យដឹងថា៖ តម្លៃលក់ចេញក្នុងស្រុក ២៧ទៅ ២៨បាត(០,៧៨-០,៨១ដុល្លារ)/គីឡូក្រាម។ ប្រេស៊ីលប្រទេសផលិតស្ករច្រើនបំផុតលើពិភពលោក បានកាត់បន្ថយការផលិតអេតាណុលពីដើមអំពៅ ដើម្បីបង្កើនការផលិតស្ករ។
- កៅស៊ូធម្មជាតិ៖ តម្លៃកៅស៊ូធម្មជាតិប្រភេទ RSS2 លក់ចេញនៅទីផ្សារតូក្យូប្រទេសជប៉ុននៅក្នុងខែសីហា នេះបានកើនឡើងជាមធ្យម៣១៥ដុល្លារ/តោន(១៥,៤៤%)ធៀបខែមុន ដោយលក់ចេញក្នុងតម្លៃមធ្យម ២.៣៥៥,០០ដុល្លារ/តោន(FOB, តូក្យូ)។ តម្លៃកៅស៊ូនាំចេញ បានកើនឡើងដល់តម្លៃខ្ពស់បំផុតធៀបក្នុងរយៈពេល១៣ឆ្នាំមុន ដោយសារប្រភពផ្គត់ផ្គង់ពិភពលោកថយចុះ និងតម្រូវការកើនឡើង។ ប្រភពផ្គត់ផ្គង់កៅស៊ូពីប្រទេសថៃ(ប្រទេសផលិតកៅស៊ូច្រើន)ធ្លាក់ចុះ ដោយសារអាកាសធាតុមិនអំណោយផល គឺមានគ្រោះទឹកជំនន់នៅតំបន់ដាំកៅស៊ូច្រើនមួយចំនួន។ បើតាមសេចក្តីប្រកាសថ្មីបំផុតរបស់សមាគមផលិតកៅស៊ូធម្មជាតិ(ANRPC) បានឲ្យដឹងថា៖ នៅក្នុងឆ្នាំ២០២៤ តម្រូវការកៅស៊ូពិភពលោកនឹងកើនឡើងដល់ចំនួន ១៥,៧៤លានតោន ហើយប្រភពផ្គត់ផ្គង់មានចំនួនត្រឹមតែ ១៤,៥លានតោនប៉ុណ្ណោះ។ នៅក្នុងឆ្នាំនេះទីផ្សារកៅស៊ូធម្មជាតិនឹងមានការខ្វះខាតចំនួន ១,២៤លានតោន គឺ ខ្ពស់ជាងការព្យាករណ៍ចំនួន ១,១២ លានតោន ហើយស្ថានភាពខ្វះខាតនឹងបន្តរហូតដល់ឆ្នាំ ២០២៨ ជាមួយនឹងកំរិតខ្វះខាត ៦០០០០០ទៅ ៨០០០០០តោន/ឆ្នាំ ។

- **ប្រេងឥន្ធនៈ**

(ឯកតា៖ ដុល្លារអាម៉េរិក/ធុង)

| មុខទំនិញ | លក្ខខណ្ឌ ប្រគល់-ទទួល | ខែកក្កដា ឆ្នាំ២០២៤ | ខែសីហា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| ប្រេងឆៅBrent | FOB (New York) | 85.35 | 80.14 | -5.21 | -6.10 |
| ប្រេង WTI | - | 81.91 | 76.02 | -5.89 | -7.19 |
| ហ្គាសGas($/mmbtu | F0B (VN) | 2.57 | 2.14 | -0.43 | -16.73 |

- កត់សំគាល់៖ នៅក្នុងខែសីហា ឆ្នាំ២០២៤នេះ តម្លៃប្រេងឥន្ធនៈមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ និងជាពិសេសតម្លៃប្រេងឆៅ។
- តម្លៃប្រេងឆៅ(Brent)៖ នៅទីផ្សារក្រុងញ៉ូយកតម្លៃប្រេងឆៅ Brent បានថយចុះ៥,២១ដុល្លារ/ធុង (៦,១០%) ដោយលក់ចេញក្នុងតម្លៃជាមធ្យម ៨០,១៤ដុល្លារ/ធុង(FOB London)។ នៅក្នុងខែសីហានេះ តម្លៃប្រេងឆៅ Brent បានថយចុះជាមធ្យម ៦,១០% ក្រោយពីតួលេខស្ថិតិ បានបង្ហាញឲ្យដឹងថា បរិមាណផលិតផលប្រេងស្តុកឃ្លាំងរបស់អាមេរិកបានកើនឡើង ៨៤៦០០០ធុង និងនៅមជ្ឈមណ្ឌលចំរាញ់ប្រេង Amsterdam-Rotterdam -Antwerp (ARA) របស់អឺរ៉ុប បានកើន ១,១% ជាមធ្យម។

- **លោហៈ**

(ឯកតា៖ ដុល្លារអាម៉េរិក)

| មុខទំនិញ | លក្ខខណ្ឌ ប្រគល់-ទទួល | ខែកក្កដា ឆ្នាំ២០២៤ | ខែសីហា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| មាស ( $ / ounce ) | Hong Kong | 2,359.50 | 2,544.00 | 184.5 | 7.82 |
| មាស ( $ / ounce ) | London | 2,365.00 | 2,517.18 | 152.18 | 6.43 |
| មាស ( $ / ounce ) | New York | 2,367.00 | 2,575.00 | 208 | 8.79 |
| Platinum($/ounce) | - | 994.46 | 979.00 | -15.46 | -1.55 |
| Palladium($/ounce | New York | 964.30 | 941.15 | -23.15 | -2.40 |
| ប្រាក់($/troy ounce) | London | 31.02 | 29.88 | -1.14 | -3.68 |

(ឯកតា៖ ដុល្លារអាម៉េរិក)

| | | | | | |
|---|---|---|---|---|---|
| ប្រាក់($/troy ounce) | New York | 30.50 | 29.05 | -1.45 | -4.75 |
| ស្ពាន់($/tons) | FOB London | 9,599.00 | 9,244.00 | -355 | -3.70 |
| អាលុយមីញ៉ូម(Al) ($/tons) | - | 2,524.50 | 2,457.50 | -67 | -2.65 |
| ស័ង្កសី(Zinc)($/tons) | FOB London | 2,937.50 | 2,878.00 | -59.5 | -2.03 |
| សំណប៉ាហាំង(Tin) ($/tons) | - | 32,739.00 | 32,345.00 | -394 | -1.20 |
| នីកែល(Nickel)(ដុល្លារ/តោន) | - | 16,942.74 | 16,417.00 | -525.74 | -3.10 |

- កត់សំគាល់៖ តម្លៃទំនិញលោហៈ មានការប្រែប្រួលទៅតាមប្រភេទនីមួយៗ ជាពិសេសតម្លៃមាស។ នៅលើទីផ្សារអន្តរជាតិ តម្លៃមាសបានកើនឡើងធៀបទៅនឹងខែមុន នៅទីក្រុងឡុងដ៍តម្លៃមាសលក់ចេញបានកើន ១៥២,១៨ដុល្លារ/Ounce(៦,៤៣%) ដោយលក់ចេញក្នុងតម្លៃ ២.៥១៧,១៨ USD/Ounce និងនៅហុងកុង តម្លៃមាសលក់ចេញកើន ១៨៤,៥០ដុល្លារ/ធុង(៧,៨២%) ដោយលក់ចេញក្នុងតម្លៃ ២.៥៤៤,០០USD/Ounce ។

ប្រភព៖ (Website Vinanet)

# ២. អត្ថបទស្រាវជ្រាវ

### ▲ ការជំរុញការដាក់ផលិតផលកម្ពុជានៅលើទីផ្សារអនឡាញដ៏ធំលើពិភពលោក អាលីបាបា៖

ការជំរុញការដាក់ផលិតផលកម្ពុជានៅលើទីផ្សារអនឡាញដ៏ធំលើពិភពលោក អាលីបាបា ជាការពិតណាស់កុំថាឡើយសូមបីតែពាណិជ្ជករ អាជីវករ វិនិយោគិន ដែលស្គាល់អាលីបាបា ជាប្រជាជនទូទៅទាំងក្នុងស្រុក និងពិភពលោក ដែលបានប្រើនូវប្រព័ន្ធតិចណូឡូជី(Technology) ប្រាកដជាស្គាល់ទីផ្សារអនឡាញដ៏ធំរបស់ពិភពលោកមួយនេះ។ បច្ចុប្បន្នក្រោយពីមានកិច្ចព្រមព្រៀងជាមួយកម្ពុជា ក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុនអាលីបាបា គឺយើងសង្កេតឃើញថាមានទំនិញកម្ពុជាមួយចំនួន បានចាប់ផ្តើមដាក់លក់នៅលើទីផ្សារអនឡាញដ៏ធំរបស់ពិភពលោក។

វឌ្ឍនភាពថ្មីៗ និងលក្ខខណ្ឌមួយចំនួន ថាតើអាជីករមួយចំនួន ដែលមានផលិតផលដាក់លក់អនឡាញតាមវិធីសាស្ត្រណាខ្លះ? តាមប្រសាស៍របស់ **ឯកឧត្តម ប៉ែន សុខជាតិ** រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យរបស់ក្រសួងពាណិជ្ជកម្មបានឲ្យដឹងថា៖ ការខិតខំប្រឹងប្រែងរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីឲ្យទំនិញកម្ពុជាឈានទៅកាន់ទីផ្សារអន្តរជាតិ តាមការប្រើប្រាស់ប្រព័ន្ធ Platform រឺប្រព័ន្ធអនលាញរបស់ក្រុមហ៊ុនអន្តរជាតិធំៗ ដូចជាក្រុមហ៊ុនអាលីបាបា។ នៅក្នុងទស្សនៈកិច្ចរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **សម្តេច**បានចូលរួមក្នុងវេទិកាខ្សែក្រវាត់ និងផ្លូវ ដោយ **សម្តេច** ធ្វើជាអធិបតីក្នុងការចុះអនុសារណៈមួយរវាងក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុនអាលីបាបា គឺបានចុះហត្ថលេខាដោយ **លោកជំទាវចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងលោកនាយកប្រតិបត្តិក្រុមហ៊ុន អាលីបាបា ផ្នែកទីផ្សារ គឺលោកស្រី វ៉ែង ជា។ គោលបំណងតែមួយគត់របស់ **លោកជំទាវ**គឺចង់ឲ្យអន្តរជាតិបានស្គាល់ទំនិញកម្ពុជា និងឲ្យទំនិញរបស់កម្ពុជាបានដាក់លក់ក្នុងភាពប្រកួតប្រជែងជាមួយនឹងមុខទំនិញដ៏ទៃទៀតដែលមានតម្រូវការ និងមានសក្តានុពលនៅលើទីផ្សារអន្តរជាតិ ដែលជាគោលដៅចំម្បង

ជំហ៊ានទីពីរយើងក៏ចង់ឲ្យសហគ្រាសធុនតូច និងមធ្យម ដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចកាន់តែមានលទ្ធភាពផលិតទំនិញកាន់តែច្រើនមុខហើយសំបូរបែបថែមទៀត។ ប្រសិនបើមានតម្រូវការនឹងអាចមានការផលិតកាន់តែច្រើនឡើង ហើយផលិតទំនិញនឹងមានតម្លៃអាចនឹងធ្វើការប្រកួតប្រជែងបានជាមួយនឹងទំនិញរបស់ប្រទេសដ៏ទៃ។

កន្លងមកក្រុមហ៊ុនអាលីបាបា បានដាក់លក់ទំនិញកម្ពុជារួចទៅហើយ ដោយធ្វើការសាកល្បងប៉ុណ្ណោះ ដូចជាទំនិញកសិផល មាន ផ្លែមានប៉ៃលិន ផ្លែស្វាយ គ្រាប់ស្វាយចន្ទី ។ល។ ហើយទំនិញទាំងនោះបានស្រូបទាញតម្រូវការពីអតិថិជនជាច្រើនផងដែរ ទន្ទឹមនោះក្រុមហ៊ុនមានបំណងចង់បានមុខទំនិញជាច្រើនមុខថែមទៀត គឺអាចពង្រីកទីផ្សារឲ្យកាន់តែធំឡើងៗ។ អាលីបាបាមានអតិថិជនរបស់ខ្លួនចំនួន ១៣០០លាននាក់ ដែលចេញចូលសរុបជាខ្សែច្រវ៉ាក់ប្រចាំថ្ងៃ ដែលជាឳកាសល្អសំរាប់យើងបើកច្រកទីផ្សារទៅកាន់ពិភពលោក និងជាក្តីបំណងរបស់ក្រសួង ក៏ដូចជាប្រមុខរាជរដ្ឋាភិបាល គឺពង្រឹងទីផ្សារចាស់ និងពង្រីកទីផ្សារថ្មី។ ដូច្នេះហើយការពង្រីកទីផ្សារថ្មីៗយើងគោរពទៅ តាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ការប្រើប្រាស់ប្រពន្ធ័អនុគ្រោះផ្សេងៗ ដែលយើងបានអនុវត្តន៍កន្លងមក ។

រាជរដ្ឋាភិបាលនៅក្នុងដំណាក់កាលអនុវត្តយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទីមួយ គឺរដ្ឋាភិបាលឌីជីថល មនុស្សឌីជីថល ធុរៈកិច្ចឌីជីថល ដូចនេះក្រសួងពាណិជ្ជកម្មត្រូវតែប្រើប្រាស់បច្ចេកវិទ្យាទាន់សម័យឌីជីថល ដែលយើងមានច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រពន្ធ័អេឡិចត្រូនិចដែលមានការីកចំរើនគួឲ្យកត់សំគាល់។ការប្រើប្រាស់សុះសលមេឌាវេសបុក ប្រព័ន្ធក្នុងស្រុកផ្សេងៗ ដើម្បីដាក់លក់ទំនិញរបស់ខ្លួន ហើយដោយឡែកអាលីបាបា ជាជំហ៊ានថ្មីមួយទៀតដែលក្រសួងពាណិជ្ជកម្មសំរេចថា នឹងជំរុញដើម្បីផ្សារភ្ជាប់ Platform ទីផ្សារផ្ទាល់ខ្លួន ដែលយើងមានរួចហើយ គឺខេមបូឌាត្រេដ ដើម្បីភ្ជាប់ទំនិញក្នុងស្រុកបានទៅដល់ដែបរទេស និងអាចឲ្យពាណិជ្ជករក្នុងប្រទេសអាចទិញទំនិញលើ Platform ទាំងពីរនេះផងដែរ។

ក្រោយពីយើងបានចុះអនុសារណៈរួចហើយ យើងក៏បានធ្វើសិក្ខាសាលាមួយទៀតនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ ដែលលោកជំទាវរដ្ឋមន្ត្រី ជាអធិបតី ដោយមានការអញ្ជើញសហគ្រាសធុនតូច និងមធ្យមក្នុងស្រុក ដែលជាដៃគួរសំខាន់ និងមានសក្តានុពលក្នុងការនាំចេញ ដើម្បីទទួលបានពត៌មានអំពីលក្ខខណ្ឌ័មួយចំនួនក្នុងការដាក់លក់ទំនិញ លើ Platform អាលីបាបា។ ពេលចាប់ផ្តើមដំបូងយើងទទួលបានក្រុមហ៊ុនចំនួន ១៥ ប៉ុណ្ណោះ បន្ទាប់ពីការពិនិត្យម៉ត់ចត់ គឺយើងមានរហូតដល់ ៣២៥៣ក្រុមហ៊ុនផ្គត់ផ្គង់ទំនិញដល់អាលីបាបា ដែលជាក្រុមហ៊ុនក្នុងទ្រង់ទ្រាយផ្សេងៗ គ្នា ដែលជាសមិទ្ធិផលក្រោយពីយើងបានចុះអនុសារណៈហើយ។ ទំនិញដែលយើងបាន ដាក់លក់មានទំនិញកសិកម្ម ទំនិញឧស្សាហម្មស្រាល ទំនិញសំលៀកបំពាក់ ទំនិញស្បែកជើង ទំនិញសិប្បកម្ម........ដែលជាបំណងប្រាថ្នារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើនតម្លៃបន្ថែមដល់ប្រជាកសិករ ពាណិជ្ជករ ពលរដ្ឋកម្ពុជា។ នៅក្នុងខែកញ្ញាខាងមុខ នាឳកាសពិពណ៌អាស៊ាន-ចិន កម្ពុជានឹងបង្កើតពន្លាជាតិមួយដែលនៅក្នុង Platform នេះ យើងនឹងធ្វើការបើកសម្ពោធបង្ហាញឲ្យអន្តរជាតិស្គាល់ថាយើងមានទំនិញដែលមានគុណភាព មាននិរន្តភាពនៃការផ្គត់ផ្គង់ ទំនិញដែលអាចបង្កើនតម្លៃបន្ថែមដល់សហគ្រាសធុនតូច និងមធ្យម ដែលអាចធ្វើការប្រកួតប្រជែងនៅលើទីផ្សារពិភពលោក។

ក្រៅអំពីប្រយោជន៍ក្នុងការបញ្ជ្រាបទីផ្សារ ពាណិជ្ជកម្មនឹងនាំមកនូវភាពរះភាព ភាពជាដៃគួរ ពីព្រោះគ្មានអ្វីប្រសើរជាងសេដ្ឋកិច្ចពាណិជ្ជកម្ម ដែលអាចភ្ជាប់ទំនាក់ទំនងបានងាយ និងផ្តល់ផលប្រយោជន៍ឲ្យគ្នាទៅវិញទៅមក ដែលនឹងអាចក្លាយទៅជាទំនាក់ទំនងការទូត គឺកាន់តែរឹងមាំ និងស៊ីជំរៅ ដែលជាសេចក្តីប្រាថ្នារបស់ប្រមុខរាជរដ្ឋាភិបាល។

កត្តាដែលជាឧបសគ្គរបស់យើងនាពេលបច្ចុប្បន្ន គឺដើមទុន បច្ចេកទេស ការកសាងឈ្មោះម៉ាកសញ្ញា ជាបញ្ហាប្រឈមចំពោះមុខ ហើយក្រសួងពាណិជ្ជកម្មក៏បានចូលរួមក្នុងការខិតខំប្រឹងប្រែងជំរុញឲ្យមានម៉ាកសញ្ញាកាន់តែច្រើននៅលើទីផ្សារអន្តរជាតិ។ មុននឹងទំនិញកម្ពុជាឈានជើងចូលទៅកាន់ទីផ្សារអាលីបាបា គឺក្រុមហ៊ុនបានទទួលស្គាល់រួចទៅហើយថា ទំនិញកម្ពុជាអាចនឹងអភិវឌ្ឍន៍ខ្លួន ពង្រីកវិសាលភាពជាក់ស្តែងបានកើនឡើងពី ១៦០០ប្រភេទ កើនដល់ ២៦៧៣៦ផលិតផល។ ទន្ទឹមនឹងឧបសគ្គខាងលើ យើងក៏ជួបប្រទះនូវឧបសគ្គមួយចំនួនទៀតដូចជា៖ ការរក្សាគុណភាពរក្សានិរន្តរភាពក្នុងការផ្គត់ផ្គង់ រក្សាការដឹកជញ្ជូន ឧបសគ្គក្នុងការផលិត( ពូជ ការប្រើប្រាស់ជី ថ្នាំសំលាប់សត្វល្អិត) ផលិផលកសិកម្មត្រូវឆ្លងកាត់វិញ្ញាបនបត្រភូតគាមអនាម័យជាដើម។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏ក្រសួងពាណិជ្ជកម្ម ខិតខំសំរួលឲ្យកាន់តែមានលក្ខណៈងាយស្រួលដល់ការចរាចរនៅលើទីផ្សារជារូបវន្ត លើទីផ្សារអនឡាញផងដែរ៕

ប្រភព: ក្រសួងពាណិជ្ជកម្ម

# ៣. ព័ត៌មានរបស់ក្រសួងពាណិជ្ជកម្ម

**លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងពិនិត្យលទ្ធភាពក្នុងការធ្វើសន្ធានកម្មតភ្ជាប់ប្រព័ន្ធគ្រប់គ្រងវិនិយោគ** (Investment Project Application–IPA) **របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្រោមអធិបតីភាព ឯកឧត្តមស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានវត្តមានអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ**

(ភ្នំពេញ)៖ នាថ្ងៃចន្ទ ៨ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងពិនិត្យលទ្ធភាពក្នុងការធ្វើសន្ធានកម្មតភ្ជាប់ប្រព័ន្ធគ្រប់គ្រងវិនិយោគ (Investment Project Application – IPA) របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានវត្តមានអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://www.moc.gov.kh/news/2058

**លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានអនុញ្ញាតជូនឯកឧត្តម** Shaharuddin Bin Onn **ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសម៉ាឡេស៊ី ប្រចាំព្រះរាជា-ណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ**

(ភ្នំពេញ)៖ នាព្រឹកថ្ងៃអង្គារ ទី១៣ ខែសីហា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអនុញ្ញាតជូនឯកឧត្តម Shaharuddin Bin Onn ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសម៉ាឡេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

ក្នុងជំនួបនេះ ភាគីទាំងពីរបានពិភាក្សានិងផ្លាស់ប្តូរយោបល់គ្នាពីកាលានុវត្តភាពក្នុងការជំរុញពាណិជ្ជកម្ម ការវិនិយោគទ្វេភាគី និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងម៉ាឡេស៊ីជាពិសេសក្នុងវិស័យហាឡាល និងលទ្ធភាពបង្កើតគណៈកម្មាធិការពាណិជ្ជកម្មចម្រុះកម្ពុជា-ម៉ាឡេស៊ី។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/2065

**លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អនុញ្ញាតជូនប្រធានតំណាងអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន** (JETRO) **ប្រចាំនៅរាជធានីភ្នំពេញ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ**

(ភ្នំពេញ)៖ នាព្រឹកថ្ងៃចន្ទ ទី១៩ ខែសីហា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អនុញ្ញាតជូន លោកស្រី Marisa Haruta ប្រធានតំណាងអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) ចូលជួបសម្តែងការគួរសម ពិភាក្សាការងារ ជម្រាបលា និងណែនាំ លោក Wakabayashi Ko Hei ដែលជាប្រធានតំណាងថ្មីរបស់អង្គការ JETRO ប្រចាំកម្ពុជា ជូន លោកជំទាវរដ្ឋមន្ត្រី។

នៅក្នុងជំនួបនេះ ភាគីទាំងពីរបានបង្ហាញនូវក្តីសោមនស្សរីករាយ និងសម្តែងការកោតសរសើរដល់កិច្ចសហប្រតិបត្តិការល្អដែលក្រសួងពាណិជ្ជកម្ម និងអង្គការ JETRO បានធ្វើរួមគ្នា នាពេលកន្លងមក និងសង្ឃឹមថាភាគីទាំងពីរនឹងបន្តនូវទំនាក់ទំនងល្អនេះ បន្ថែមទៀតនាពេលអនាគត ក្នុងគោលបំណងជំរុញធុរកិច្ច និងពាណិជ្ជកម្មរវាងកម្ពុជា និងជប៉ុន ឱ្យកាន់តែល្អប្រសើរបន្ថែមទៀត។ ជាមួយគ្នានេះ ភាគីទាំងពីរបានឯកភាព ពិនិត្យឡើងវិញនូវអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងពាណិជ្ជកម្ម និងអង្គការ JETRO ដែលបានចុះហត្ថលេខានាពេលកន្លងមក។ សូមចូលអានព័ត៌មានលំអិតតាមរយៈ https://www.moc.gov.kh/news/2091

**ឯកឧត្តម ពេជ ឫទ្ធី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ស្តីពីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន លើកទី៤៦** (46th HLTF-EI) **នៅរដ្ឋធានីវៀងចន្ទន៍ ប្រទេសឡាវ**

(វៀងចន្ទន៍, ឡាវ) ៖ នាថ្ងៃទី១៣-១៤ ខែសីហា ឆ្នាំ២០២៤ នៅរដ្ឋធានីវៀងចន្ទន៍ ប្រទេសឡាវ ឯកឧត្តម ពេជ ឫទ្ធី រដ្ឋលេខាធិការ និងជា HLTF-EI Lead តំណាងកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ស្តីពីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន លើកទី៤៦ (46th HLTF-EI)។

កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងក្រោមភាពជាប្រធានអាស៊ានរបស់ឡាវ ឆ្នាំ២០២៤ ដើម្បីពិភាក្សា និងតាមដានវឌ្ឍនភាពការងារនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន រួមមាន៖ អាទិភាពសេដ្ឋកិច្ចក្រោមភាពជាប្រធានអាស៊ានរបស់ឡាវ ទិដ្ឋភាពទូទៅនៃសេដ្ឋកិច្ចតំបន់និងសកល យុទ្ធសាស្ត្រអាស៊ានស្តីពីអព្យាក្រឹត្យភាពកាបូន ផែនការយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៦-២០៣០ សម្រាប់ទស្សនវិស័យ សហគមន៍អាស៊ានឆ្នាំ២០៤៥ ការត្រួតពិនិត្យឡើងវិញចុងក្រោយលើផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ ។ល។ ជាពិសេសដើម្បីរៀបចំនូវអនុសាសន៍ជូនកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន លើកទី៥៦ ដែលនឹងរៀបចំឡើងនៅខែកញ្ញា ឆ្នាំ ២០២៤ ខាងមុខ។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://www.moc.gov.kh/news/2079

**ឯកឧត្តម សំហេង បូរ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីបើកសម្ពោធពិព័រណ៍អន្តរជាតិ** «BCG THAI FESTIVE FAIR 2024» **នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ ដែលមានវត្តមានអញ្ជើញចូលរួមពី ឯកឧត្តម** CHERDKIAT Atthakor **ឯកអគ្គរាជទូតថៃប្រចាំកម្ពុជា ឯកឧត្តមឧកញ៉ា ងួន ម៉េងតិច អគ្គនាយកសភាពាណិជ្ជកម្មកម្ពុជា និង ឯកឧត្តម លោកជំទាវតំណាងវិស័យឯកជន រួមទាំងពាណិជ្ជករថៃជាច្រើនរូប**

(ភ្នំពេញ)៖ នារសៀលថ្ងៃព្រហស្បតិ៍ ទី១៥ ខែសីហា ឆ្នាំ២០២៤ ឯកឧត្តម សំហេង បូរ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីបើកសម្ពោធពិព័រណ៍អន្តរជាតិ «BCG THAI FESTIVE FAIR 2024» នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ ដែលមានវត្តមានអញ្ជើញចូលរួមពីឯកឧត្តម CHERDKIAT Atthakor ឯកអគ្គរាជទូតថៃប្រចាំកម្ពុជា ឯកឧត្តមឧកញ៉ា ងួន ម៉េងតិច អគ្គនាយកសភាពាណិជ្ជកម្មកម្ពុជា និង ឯកឧត្តម លោកជំទាវតំណាងវិស័យឯកជន រួមទាំងពាណិជ្ជករថៃជាច្រើនរូប។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://www.moc.gov.kh/news/2082

**ឯកឧត្តម ទិត រិទ្ធីពល អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំលើកទី៨ នៃគណៈកម្មាធិការចម្រុះចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហាឡុង ប្រទេសវៀតណាម**

(ហាឡុង, វៀតណាម)៖ នាថ្ងៃទី៥-៩ ខែសីហា ឆ្នាំ២០២៤ នៅទីក្រុងហាឡុង ខេត្តក្វាងនិញ នៃប្រទេសវៀតណាម ឯកឧត្តម ទិត រិទ្ធីពល អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មាធិការចម្រុះសម្រាប់ភាគីកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំលើកទី៨ នៃគណៈកម្មាធិការចម្រុះចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងកិច្ចប្រជុំពាក់ព័ន្ធ ក្នុងគោលបំណងពិនិត្យតាមដានវឌ្ឍនភាពនៃការចរចា និងពិភាក្សាដោះស្រាយបញ្ហានានារបស់ក្រុមការងារពាក់ព័ន្ធ ដើម្បីឈានទៅរកការបញ្ចប់ការចរចាដំឡើងកម្រិត នៅចុងឆ្នាំ២០២៤ តាមការគ្រោងទុក។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/1985

# ៤.ព័ត៌មានទីផ្សារអន្តរជាតិ

## ▲ ខឿនសេដ្ឋកិច្ចទីពីរលើពិភពលោកកំពុងជំរុញវិស័យផលិតបន្ទះឈីប(chip)៖

នៅក្នុងឧបករណ៍អេឡិចត្រូនិចទាំងអស់ សុទ្ធសឹងតែមានបំពាក់នូវបន្ទះឈិប (chip) ហើយជាទូទៅការផលិតបន្ទះឈីប (chip) តែងតែមានដំណើរការស្មុគស្មាញ និងតម្រូវឲ្យមានការយកចិត្តដាក់ ជាមួយនឹងស្តង់ដារខ្ពស់។ ការចំណាយ និងភាពលំបាកនៅក្នុងការផលិតបានជំរុញឲ្យក្រុមហ៊ុនអេឡិចត្រូនិចពឹងផ្អែកកាន់ តែខ្លាំងឡើងលើរោងចក្រផលិតក្នុងការផ្គត់ផ្គង់បន្ទះឈិប(chip)ឲ្យខ្លួន។ វិបត្តិបន្ទះឈិបបានធ្វើឲ្យឧស្សាហកម្មយ៉ាងហោចណាស់ចំនួន១៦៩ បានរងផលប៉ះពាល់ ដោយសារតែកង្វះការផ្គត់ផ្គង់បន្ទះឈីប(chip)ជុំវិញពិភពលោក។ កង្វះខាតបន្ទះឈីប(chip) ជាសកលបានបង្កឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំងទៅដល់ក្រុមហ៊ុនអេឡិចត្រូនិច នៅជុំវិញពិភពលោក ដោយសារតែវាផ្តល់ផលវិបាកក្នុងការបំពេញ នូវតម្រូវការទំនិញ និងគ្រឿងអេឡិចត្រូនិចដែលមានការកើនឡើងយ៉ាងគំហុក។

**អ្វីទៅជាបន្ទះឈីប**(chip)?

បន្ទះឈិប(chip) គឺជាបំណែកតូចមួយនៃសម្ភារៈ semiconducting ដែលជាទូទៅវាធ្វើឡើងពីស៊ីលីកូ (silicon) ហើយបង្កប់ជាមួយសៀគ្វីរួមបញ្ចូលគ្នា(Integrated circuit)។ ជាមួយនឹងភាពជឿនលឿននៃបច្ចេកវិទ្យាបន្ទះឈីប (chip) គឺជាឧបករណ៍ដ៏សំខាន់ដែលជាឆ្អឹងខ្នងនៃឧស្សាហកម្មសំខាន់ៗជាច្រើន រាប់ចាប់ពី វិស័យថែទាំសុខភាពរហូតដល់វិស័យកសិកម្មរាប់ពាន់លាន ព្រមទាំងវិស័យស្មាតហ្វូន កុំព្យូទ័រ ឧបករណ៍ឆ្លាតវៃ យានយន្ត ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ ឧបករណ៍ជួយសង្គ្រោះជីវិត អេធីអឹម (ATM) ។ល។ ផលពិបាកនៅក្នុងការផលិតបន្ទះឈីប(chip)នេះ បានក្លាយជាប្រធានបទដ៏ក្តៅគគុកមួយនៃផ្នែកបច្ចេកវិទ្យាទំនើប។ ក្រុមហ៊ុនល្បីៗមួយចំនួនដែលផលិតបន្ទះឈីប(chip) អេឡិចត្រូនិចមានដូចជា៖ Intel, Samsung, Taiwan Semiconductor Manufacturing Company (TSMC), Broadcom និង Nvidia យ៉ាងណាមិញ ៨៧% នៃការផលិតបន្ទះឈិប(chip) នៅជុំវិញពិភពលោកមានមូលដ្ឋាននៅតៃវ៉ាន់ កូរ៉េខាងត្បូង និងចិន។ នៅក្នុងពិភពឌីជីថលបន្ទះឈិប(chip) គឺជាសរសៃឈាមនៃផលិតកម្មអេឡិចត្រូនិច ខណៈដែលការប្រើប្រាស់រថយន្តធ្លាក់ចុះ ដោយសារស្ថានភាពសេដ្ឋកិច្ចបណ្តាលឲ្យក្រុមហ៊ុនផលិតបន្ទះឈីប(chip) បានផ្តោតជាសំខាន់ទៅលើកម្មវិធីដែលមិនមែនជាយានយន្តដូចជា៖ កុំព្យូទ័រ ប្រពន្ធ័ទំនាក់ទំនងផ្សេងៗ ដែលមានតម្រូវការច្រើនជាង។

**តើវិបត្តិកង្វះបន្ទះឈីប**(chip) **បានជះឥទ្ធិពលអ្វីខ្លះ**?

ឧស្សាហកម្មផ្សេងៗត្រូវបានរងផលប៉ះពាល់ដោយសារតម្រូវការបន្ទះឈិប(chip) អេឡិចត្រូនិចសកលបន្តកើនឡើងលើសពីការផ្គត់ផ្គង់។ សម្រាប់ក្រុមហ៊ុនដែលពឹងផ្អែកលើបន្ទះឈីប(chip) បានរងការខ្វះខាតបណ្តាលឲ្យមានការរាំងស្ទះដល់ខ្សែសង្វាក់ផ្គត់ផ្គង់ដែលបង្ខំឲ្យឧស្សាហកម្មជាច្រើនសម្រេចផ្អាក រឺបញ្ឈប់ការផលិតមួយរយៈ។

**តើមានដំណោះស្រាយបែបណាសម្រាប់ការផ្គត់ផ្គង់បន្ទះឈិប**(chip)**សកល**?

វិបត្តិបន្ទះឈិប(chip)សកល គឺជាការដាស់តឿនប្រទេសនៅជុំវិញពិភពលោកអំពីសារៈសំខាន់ នៃឧបករណ៍អេឡិច-ត្រូនិច សម្រាប់អនាគតមនុស្សជាតិ។ កន្លងមកការប្រឈមមុខនឹងកង្វះខាតបន្ទះឈិប(chip)បានដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរដល់រដ្ឋាភិបាលក្រុមហ៊ុនផលិតរថយន្ត និងអ្នកផលិតបន្ទះឈិប(chip) ដើម្បីស្វែងរកដំណោះស្រាយ។ យ៉ាងណាមិញរដ្ឋាភិបាលរបស់ប្រទេសមួយចំនួនជុំវិញពិភពលោក បានប្តេជ្ញាចិត្តក្នុងការចំណាយដើមទុន និងកំពុងបន្តគោលនយោបាយ ដើម្បីបង្កើនសមត្ថភាពផលិតបន្ទះឈិប(chip) ក៏ដូចជាបង្កើតខ្សែច្រវ៉ាក់ផ្គត់ផ្គង់ក្នុងស្រុកដែលអាចជៀសផុតពីការជាប់គាំង។ ប្រទេសកូរ៉េខាងត្បូងបានប្រកាសកម្មវិធីវិនិយោគមួយដែលមានតម្លៃ ៤៥០ពាន់លានដុល្លារអាម៉េរិក ក្នុងរយៈពេល១០ឆ្នាំខាងមុខ ដើម្បីឧបត្ថម្ភលើការផលិត semiconductor និងបង្កើនសមត្ថភាពក្រុមហ៊ុនផលិតបន្ទះឈីប(chip)របស់ខ្លួនក្នុងការប្រកួតប្រជែងលើទីផ្សារសកល។ ទន្ទឹមនោះដែររដ្ឋាភិបាលកូរ៉េខាងត្បូងគ្រោងនឹងផ្តល់ការបន្ធូរបន្ថយពន្ធ កាត់បន្ថយអត្រាការប្រាក់ បទប្បញ្ញត្តិ និងជួយផ្តល់មូលនិធិដល់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផងដែរ។ ចំណែកឯប្រទេសចិន បានបង្កើនមូលនិធិជាតិរាប់ពាន់លានដុល្លារអាម៉េរិក ដើម្បីវិនិយោគលើក្រុមហ៊ុនផលិតបន្ទះឈីប(chip)ក្នុងស្រុក ដើម្បីតាមឲ្យទាន់សហរដ្ឋអាម៉េរិក កូរ៉េខាងត្បូង និងតៃវ៉ាន់។

បច្ចុប្បន្នរដ្ឋាភិបាលជប៉ុន ប្រទេសដែលមានខឿនសេដ្ឋកិច្ចធំទីពីរ លើពិភពលោកកំពុងពិនិត្យលើសេចក្តីព្រាងច្បាប់ “ដ៏មានសារៈសំខាន់បំផុត“ ដើម្បីការពារគាំពារខ្ទង់ប្រាក់កម្ចីរបស់ក្រុមហ៊ុនផលិតបន្ទះឈីប(chip) សម្រាប់រោងចក្រ Rapidus ដែលមានរដ្ឋាភិបាលជាខ្នងបង្អែក។ ក្រុមហ៊ុន Rapidus មានតម្រូវការនូវទឹកប្រាក់ប្រហែលជា ៣.០០០ ដល់ ៤.០០០ពាន់លានយេន (១៩-២៥ពាន់លានដុល្លារអាម៉េរិក) ជាជំនួយមុនពេលចាប់ផ្តើមខ្សែសង្វាក់ផលិតនៅតំបន់ហុកកាយដូនៅឆ្នាំ២០២៧។ រដ្ឋាភិបាលទីក្រុងតូក្យូ បានសន្យានឹងផ្តល់ទឹកប្រាក់ចំនួន ១.០០០ ពាន់លានយេន សម្រាប់ក្រុមហ៊ុន Rapidus (គឺអាស្រ័យទៅនឹងស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋ) ព្រមជាមួយនឹងការវិនិយោគរបស់ក្រុមហ៊ុនពីរទៀត គឺ Sony Group និង Toyota Motor បានវិនិយោគនូវទឹកប្រាក់ចំនួន ៧,៣ពាន់លានយេន ដែលជាចំនួនមួយតិចតួចក្នុងការផលិតឈីប(chip) ទំនើបៗ ។

នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ នាយករដ្ឋមន្ត្រីជប៉ុន លោក Fumio Kishida បានអញ្ជើញមកដល់ Hokkaido ទីកន្លែងដែលរោងចក្រ Rapidus កំពុងសាងសង់ និងនិយាយទៅកាន់អង្គពិធីទាំងមូលថា៖ តូក្យូ បោះជំហ៊ានទៅមុខឲ្យបានលឿនដើម្បីសម្រេចឲ្យបាននូវផែនការផលិតបន្ទះចំលងចរន្តសំរាប់បំរើឲ្យតម្រូវការ និងបានឆ្លុះបញ្ចាំងពីការកាត់បន្ថយសម្ពាធនៃការខ្វះខាតបន្ទះឈីប(chip) ដោយសារតែបន្ទះឈីប(chip) បន្តក្លាយជាធាតុចូលដ៏សំខាន់នៅក្នុងទីផ្សារអេឡិចត្រូនិចសកលនាពេលអនាគត។

ប្រភព៖ Website Vinanet

# អំពីព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម

ព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម គឺជាព្រឹត្តិបត្របោះពុម្ពផ្សាយដោយនាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។ ព្រឹត្តិបត្រនេះប្រមូលផ្តុំនូវមាតិកាសំខាន់ៗរួមមាន ស្ថិតិព័ត៌មានពាណិជ្ជកម្ម សន្ទស្សន៍ថ្លៃទំនិញចាំបាច់ ព័ត៌មានតម្លៃទំនិញសំខាន់ៗ លើទីផ្សារពិភពលោក និងអត្ថបទស្រាវជ្រាវ។

## សមាសភាពថ្នាក់ដឹកនាំ និងក្រុមការងារ

១- ឯកឧត្តម ប៉ែន សុវិជាតិ
២- លោកជំទាវ សេរី បូរាពេជ្រ
៣- លោក គន់ ឌីរ៉ង់
៤- លោកស្រី ឡុង លាបភា
៥- លោកស្រី ធន សាល័ក្ខណ៍
៦- លោកស្រី ថាច់ ម៉ារីយ៉ា
៧- លោក យឹម រ៉ុម
៨- លោក ស៊ិន សុខហេង
៩- លោក សេង សុគន្ធា (អ្នករចនា)

## សូមស្កេន QR Code ដើម្បីភ្ជាប់ទៅ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម

Website
www.moc.gov.kh

Facebook
@moc.gov.kh

Telegram
@mocnewsfeed

YouTube
@mocgovkhcambodia

X Account
@MoCCambodia

ដីឡូត៍ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣ បេ) ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភ្នំពេញ ១២១០២
Lot 19-61 MOC Road (113B Road) Phum Teuk Thla , Sangkat Teuk Thla , Khan Sen Sok, Phnom Penh 12102
Email : dpsti.bulletin@moc.gov.kh